# សេចក្តីថ្លែងការណ៍រួម
# ភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨

## អង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យច្រានចោលនូវសេចក្តីព្រាងវិសោធនកម្មលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ ខណៈដែលមានការដាក់ទណ្ឌកម្មស្របច្បាប់លើសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋកម្ពុជា

យើងខ្ញុំជាអង្គការសង្គមស៊ីវិល និងសហគមន៍ ដែលមានរាយនាមខាងក្រោម សូមសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេចក្តីស្នើរបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") និងស្នើឱ្យមានបទល្មើសប្រមាថព្រះមហាក្សត្របញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ការស្នើធ្វើវិសោធនកម្មទាំងនេះបានបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន និងធ្វើឡើងដើម្បីដាក់ទោសបន្ថែមទៀតទៅលើបុគ្គល ឬក៏ស្ថាប័នណាដែលហ៊ានបញ្ចេញមតិផ្ទុយដោយស្របច្បាប់។ យើងមានក្តីបារម្ភយ៉ាងខ្លាំងចំពោះចេតនា ដើម្បីបដិសេធសេរីភាពមូលដ្ឋានរបស់ប្រជាជនកម្ពុជាដែលទទួលបានការការពារដោយច្បាប់ និងអំពាវនាវឱ្យច្រានចោលនូវសេចក្តីព្រាងវិសោធនកម្មទាំងនេះ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ រដ្ឋសភាបានអនុម័តលើសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន ៥ មាត្រា[1] ដែលអាចជះផលមិនល្អសម្រាប់ប្រជាពលរដ្ឋកម្ពុជា ប្រសិនបើសេចក្តីស្នើច្បាប់នេះត្រូវបានអនុម័ត។ វិសោធនកម្មនេះនឹងបង្កើតជារនាំងមិនច្បាស់លាស់ ដែលអាចគំរាមកំហែងដើម្បីដាក់កំហិតការអនុវត្តសិទ្ធិ និងសេរីភាពមូលដ្ឋាន។ វិសោធនកម្មមាត្រា ៤៩ ហាមឃាត់ពលរដ្ឋកម្ពុជាពី "សកម្មភាពណាមួយ" ដែល "ប៉ះពាល់ផលប្រយោជន៍" របស់ព្រះរាជាណាចក្រកម្ពុជា ឬពលរដ្ឋខ្មែរ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ បទបញ្ញត្តិនេះមានលក្ខណៈទូលំទូលាយពេក និងពុំបានកំណត់និយមន័យច្បាស់លាស់ មានន័យថាសកម្មភាពស្របច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋានអាចនឹងត្រូវហាមឃាត់ប្រសិនបើគេបកស្រាយថា "ប៉ះពាល់ផលប្រយោជន៍"។ ការហាមប្រាមស្រដៀងគ្នានេះក៏អនុវត្តទៅលើសកម្មភាពគណបក្សនយោបាយ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដ និងដែលកំពុងដំណើរការ។

ការកែប្រែមាត្រា ៣៤ នឹងអាចដកសិទ្ធិប្រជាពលរដ្ឋទាំងស្រុងក្នុងការចូលរួមបោះឆ្នោត ការកែប្រែមាត្រា ៤២ នឹងកំហិតសិទ្ធិសេរីភាពខាងសមាគម ដែលតម្រូវឱ្យមានតែការបង្កើតគណបក្សនយោបាយណាដែល "តម្កល់ផលប្រយោជន៍ជាតិជាធំ" ប៉ុណ្ណោះ ការកែប្រែមាត្រា ៤៩ នឹងបង្កើតកាតព្វកិច្ចផលប្រយោជន៍ជាតិជាធំ ដែលមានលក្ខណៈមិនច្បាស់លាស់ ខណៈដែលការកែប្រែមាត្រា ៥៣ អាចនឹងប្រឆាំងការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ទោះក្រោម "រូបភាពណាក៏ដោយ"។ វិសោធនកម្មមាត្រា ១១៨ បានលុបចោលតំណែងរដ្ឋលេខាធិការចេញពីគណៈរដ្ឋមន្ត្រី។[2] លក្ខណៈមិនច្បាស់លាស់នៃការធ្វើវិសោធនកម្មមាត្រាទាំងនេះ មានន័យថាការធ្វើវិសោធនកម្មនេះអាចនឹងត្រូវបានប្រើប្រាស់ដោយបំពាន ដើម្បីធ្វើឱ្យការដាក់

---

[1] មាត្រា៣៤, មាត្រា៤២, មាត្រា៤៩, មាត្រា៥៣, មាត្រា១១៨

[2] Andrew Nachemson and មុិច ដារ៉ា, 'រាយការណ៍បន្ថែម ៖ ច្បាប់ប្រមាថព្រះមហាក្សត្រត្រូវធ្វើវិសោធនកម្មក្នុងចំណោមរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌកម្ពុជា', ភ្នំពេញប៉ុស្តិ៍, (២ កុម្ភៈ ២០១៨, រាយការណ៍ចុងក្រោយ ៥ កុម្ភៈ ២០១៨) http://bit.ly/2nUPBs3

ទណ្ឌកម្មជាច្រើនលើការអនុវត្តសេរីភាពមូលដ្ឋានមានលក្ខណៈស្របច្បាប់ រួមទាំងការចូលរួមពិភាក្សាស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដែលកំពុងធ្លាក់ចុះយ៉ាងខ្លាំងផងដែរ។

ការធ្វើវិសោធនកម្មនេះ ធ្វើឡើងបន្ទាប់ពីដំណើរការពិគ្រោះយោបល់ផ្ទៃក្នុងដ៏ប្រញាប់ និងសម្ងាត់ដែលមិនបានស្វែងរកមតិយោបល់ពីសង្គមស៊ីវិល ឬសាធារណជនកម្ពុជាជាទូទៅ។ មុនពេលបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋាភិបាលពុំបានផ្សព្វផ្សាយសេចក្តីព្រាងវិសោធនកម្មនេះឡើយ ដែលការធ្វើបែបនេះផ្ទុយទៅនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យដែលមានការចូលរួម។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ហើយរាល់ការស្នើសុំកែប្រែណាមួយគួរតែធានាឱ្យបានថា សំឡេងប្រជាពលរដ្ឋត្រូវបានយកចិត្តទុកដាក់យ៉ាងពេញលេញ។ ដំណើរការប្រញាប់ប្រញាល់ និងសម្ងាត់បែបនេះ គឺបង្ហាញឱ្យឃើញជាក់ស្តែងពីការមិនគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យដែលធានាដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក៏ដូចជាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១។

នៅថ្ងៃទី១៤ ខែកុម្ភៈ រដ្ឋសភាជាតិក៏បានអនុម័តលើសេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដើម្បីបន្ថែមបទល្មើសថ្មីត្រង់មាត្រា ៤៣៧ ស្ទួន ស្តីពី "ការប្រមាថព្រះមហាក្សត្រ"។ "ការប្រមាថ" ត្រូវបានផ្តល់និយមន័យថាជា *"វាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល"* ។ រូបវន្តបុគ្គលដែលត្រូវផ្តន្ទាទោសតាមសេចក្តីព្រាងវិសោធនកម្មនេះប្រឈមនឹងការជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ដល់ ១០ លានរៀល។ នីតិបុគ្គល[3] អាចនឹងត្រូវផ្តន្ទាទោស និងពិន័យជាប្រាក់ពី ១០ លានរៀល ដល់ ៥០ លានរៀល។ លើសពីនេះ នីតិបុគ្គលអាចនឹងត្រូវរំលាយ ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យផ្នែកច្បាប់ និងហាមឃាត់ពីការធ្វើសកម្មភាពណាមួយ ប្រសិនបើរកឃើញថាមានទោសក្រោមបទល្មើសថ្មីនេះ។

ការធ្វើវិសោធនកម្មបែបនេះផ្ទុយនឹងធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទាំងស្រុង។ មាត្រា ១៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ការរឹតត្បិតណាមួយលើសេរីភាពក្នុងការបញ្ចេញមតិ (ដូចជាច្បាប់ប្រមាថព្រះមហាក្សត្រ) ត្រូវតែជាការចាំបាច់ និងសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ (ក្នុងករណីនេះ សិទ្ធិ ឬកិត្តិស័ព្ទអ្នកដទៃ)[4]។ នៅក្នុងករណីនេះ សេចក្តីព្រាងវិសោធនកម្មគឺមិនចាំបាច់នោះទេ ព្រោះច្បាប់បរិហារកេរ្តិ៍ និងប្រមាថដែលមានស្រាប់បានការពារព្រះមហាក្សត្ររួចទៅហើយ។ ការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរ ក៏មានភាពវិសមាមាត្រយ៉ាងទូលាយផងដែរ បើធៀបនឹងគោលបំណងស្របច្បាប់។ ភាពមិនច្បាស់លាស់នៃពាក្យពេចន៍គឺជាបញ្ហាយ៉ាងធំ ដែលនាំឱ្យមានការប្រើប្រាស់ដោយបំពាន។ ដូចបានឃើញក្នុងបណ្តាប្រទេសផ្សេងៗ ច្បាប់ប្រមាថព្រះមហាក្សត្រដែលកំណត់និយមន័យមិនច្បាស់លាស់ អាចត្រូវបានប្រើដើម្បីដៅមុខសញ្ញាលើអ្នកណាម្នាក់ដែលហ៊ានធ្វើការរិះគន់។ យោងតាមប្រសាសន៍របស់តំណាងពិសេសអង្គការសហប្រជាជាតិ ស្តីពីសេរីភាពនៃការបញ្ចេញមតិ និងគំនិត លោក ដាវីត

[3] រាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល សហជីព គណបក្សនយោបាយ និងក្រុមហ៊ុន

[4] គណៈកម្មាធិការអង្គការសហប្រជាជាតិបានលើកឡើងថា ទាក់ទងនឹងខ្លឹមសារសុន្ទរកថានយោបាយ បានផ្តល់តម្លៃឱ្យបាន "ខ្ពស់ជាពិសេស" លើសេរីភាពបញ្ចេញមតិ។ លើលពីនេះ ច្បាប់ដែលរឹតត្បិតសេរីភាពបញ្ចេញមតិត្រូវតែបង្កើតឡើងឱ្យមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីឱ្យបុគ្គលម្នាក់ៗអាចបញ្ញត្តិពីការប្រព្រឹត្តរបស់ខ្លួនទៅតាមនោះ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីព្យល់ទូទៅលេខ ៣៤ (មាត្រា ១៩) UN Doc CCPR/C/GC/៣៤ ថ្ងៃទី១២ កញ្ញា ២០១១ កថាខណ្ឌទី ៣៨ អាចរកមើលនៅ <http://cambodia.ohchr.org/sites/default/files/Softlaw/GC_34_Khmer.pdf>; គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីព្យល់ទូទៅ៣៤ (មាត្រា ១៩) UN Doc CCPR/C/GC/៣៤ ថ្ងៃទី១២ កញ្ញា ២០១១ កថាខណ្ឌទី ២៥ អាចរកមើលនៅ <http://cambodia.ohchr.org/sites/default/files/Softlaw/GC_34_Khmer.pdf>.

ខេយ៍ "បុគ្គលសាធារណៈ រួមទាំងបុគ្គលដែលមានអំណាចផ្នែកនយោបាយខ្ពស់បំផុត អាចនឹងក្លាយជាប្រធានបទនៃការរិះគន់ ហើយការពិតទៅទម្រង់នៃការបញ្ចេញមតិខ្លះដែលអាចត្រូវបានមើលឃើញថាជាការជេរប្រមាថទៅលើបុគ្គលសាធារណ តែនេះមិនមែនជាអំណះអំណាងគ្រប់គ្រាន់ដើម្បីជ្រើសរើសនៃការរិតត្បិត ឬដាក់ទោសទណ្ឌនោះទេ"។

សេចក្តីស្នើធ្វើវិសោធនកម្មទាំងនេះ ធ្វើឡើងក្នុងបរិបទវាយប្រហារជាទូទៅលើលទ្ធភាពរបស់ពលរដ្ឋកម្ពុជាក្នុងការអនុវត្តសិទ្ធិ និងសេរីភាពមូលដ្ឋាន។ ការបង្ក្រាបជាប្រព័ន្ធលើសំឡេងឯករាជ្យ រួមមានការបិទកាសែតឯករាជ្យ ស្ថានីយវិទ្យុ អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ព្រមទាំងការចាប់ និងការឃុំឃាំងអ្នកការពារសិទ្ធិមនុស្ស សបង្ហាញឱ្យឃើញនូវចេតនាពីក្រោយសេចក្តីស្នើច្បាប់ទាំងនេះ។ ការធ្វើវិសោធនកម្មនេះអាចជាអាវុធស្របច្បាប់បន្ថែមទៀតសម្រាប់រដ្ឋាភិបាល ដែលហាក់ដូចជាមានបំណងលុបបំបាត់គ្រប់ទម្រង់នៃការតវ៉ាដោយសន្តិវិធី ពហុនិយម និងការពិភាក្សានយោបាយដែលបើកចំហ។ យើងខ្ញុំសូមអំពាវនាវឱ្យអាជ្ញាធរកម្ពុជាគោរពកាតព្វកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយបដិសេធចោលនូវសេចក្តីស្នើវិសោធនកម្មទាំងស្រុង។

សេចក្តីថ្លែងការណ៍រួមនេះដោយ ៖

1. ALTSEAN-Burma
2. ASEAN Parliamentarians for Human Rights (APHR)
3. Asian Forum for Human Rights and Development (FORUM-ASIA)
4. Asian Network for Free Elections (ANFREL)
5. សហគមន៍បឹងប្រាំ
6. សហគមន៍បឹងកក់
7. សហគមន៍បឹងត្របែក
8. អនាគតយុវជនកម្ពុជាអាស៊ាន
9. អង្គការជនជាតិដើមភាគតិចកម្ពុជា
10. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
11. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា
12. សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
13. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ
14. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
15. Center for Human Rights and Development (CHRD) (Mongolia)
16. Center for Peace Education-Miriam College (Philippines)
17. សហគមន៍ជ្រោយចង្វា
18. សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម
19. សម្ព័ន្ធសហគមន៍កសិករកម្ពុជា

20. គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា
21. សហគមន៍លេខ ៩២
22. Community Resource Centre ( CRC ) ( Thailand )
23. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
24. Covenants Watch ( CW ) ( Taiwan )
25. FIDH - International Federation for Human Rights
26. Free and Fair Election Foundation of Afghanistan ( FEFA )
27. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
28. GZO Peace Institute ( Philippines )
29. Human Rights Watch ( HRW )
30. IFEX
31. IM Center for Peace and Dialogue ( Indonesia )
32. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
33. សហគមន៍យុវជនជនជាតិដើមភាគតិចប្រមេរ
34. Indonesia Legal Aid Foundation ( YLBHI )
35. សមាគមឥន្ទ្រទេវី
36. Institut Titian Perdamaian ( Indonesia )
37. Institute for Political and Electoral Reform ( IPER )
38. Judicial System Monitoring Program ( JSMP )
39. សមាគម ខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍
40. សហគមន៍ជនជាតិដើមភាគតិចគួយ ភូមិប្រមេរ ខេត្តព្រះវិហារ
41. សហគមន៍ដីធ្លី ភូមិមួយ ខេត្តព្រះសីហនុ
42. សហគមន៍ដីធ្លី ភូមិព្រែកជីក ខេត្តកោះកុង
43. សហគមន៍ជម្លោះដីធ្លី ភូមិស្គន់ ខេត្តសៀមរាប
44. លីកាដូ កាណាដា
45. អង្គការការពារសិទ្ធិជនជាតិភាគតិច
46. មាតាធម្មជាតិ
47. National Citizens' Movement for Free Elections ( Namfrel )
48. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា
49. Odhikar ( Bangladesh )
50. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព
51. People´s Empowerment Foundation ( PEF ) ( Thailand )
52. People's Action for Free and Fair Elections ( PAFFREL )
53. សហគមន៍ភ្នំបាត

54. អង្គការពន្លកខ្មែរ
55. Progressive Voice
56. សហគមន៍ផ្លូវរថភ្លើង ទួលសង្កែ A
57. Regional Coordinator for the Southeast Asian Conflict Studies Network ( SEACSN )
58. អង្គការសីលការ
59. សហគមន៍ស្ត្រីឃ្លាំងសាំង
60. Taiwan Association for Human Rights ( TAHR )
61. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់
62. Think Centre ( Singapore )
63. Transparent Election Foundation of Afghanistan( TEFA )
64. World Organisation Against Torture ( OMCT )